CALIFORNIA DEPARTMENT OF JUSTICE

OFFICE OF THE ATTORNEY GENERAL

# ឧក្រិដ្ឋកម្ម និងករណីស្អប់ខ្ពើម

## របៀបរាយការណ៍អំពីឧក្រិដ្ឋកម្ម និងករណីស្អប់ខ្ពើម និងទទួលជំនួយ

### អង្គភាពសេវាកម្មជនរងគ្រោះនៃក្រសួងយុត្តិធម៌រដ្ឋ California

លោក Rob Bonta អគ្គរដ្ឋអាជ្ញារដ្ឋ California ផ្តល់ព័ត៌មានខាងក្រោមអំពីរបៀបកំណត់ដឹង និងរាយការណ៍អំពីឧក្រិដ្ឋកម្ម និងករណីស្អប់ខ្ពើម និងសេវាកម្មដែលមានសម្រាប់ជនរងគ្រោះ។

## *ឧក្រិដ្ឋកម្មស្អប់ខ្ពើម ឬករណីស្អប់ខ្ពើម?*

មានភាពខុសគ្នារវាងឧក្រិដ្ឋកម្មស្អប់ខ្ពើម និងករណីស្អប់ខ្ពើមដូចបានពន្យល់ខាងក្រោម៖

**ឧក្រិដ្ឋកម្មស្អប់ខ្ពើម** គឺជាបទមជ្ឈិម ឬអំពើបទឧក្រិដ្ឋកម្មព្រហ្មទណ្ឌ ដែលប្រព្រឹត្តប្រឆាំងនឹងបុគ្គល ក្រុម ឬទ្រព្យសម្បត្តិដែលត្រូវបានជំរុញដោយការស្អប់ខ្ពើម ឬលម្អៀងដោយចេតនាប្រឆាំងនឹងលក្ខណៈអត្តសញ្ញាណពិតប្រាកដ ឬត្រូវបានយល់ឃើញរបស់ជនរងគ្រោះ។ លក្ខណៈអត្តសញ្ញាណដែលត្រូវបានយល់ឃើញដែលមានការការពារ រួមមានការដែលត្រូវបានចាត់ទុកជា យល់ឃើញ ឬចាត់ទុកជាលក្ខណៈមានការការពារ មិនថាតើការយល់ឃើញនោះត្រឹមត្រូវឬអត់នោះទេ។ អ្នកអាចនឹងជាជនរងគ្រោះនៃឧក្រិដ្ឋកម្មស្អប់ខ្ពើមប្រសិនបើអ្នកត្រូវបានគកំណត់គោលដៅដោយសារតែការពិត ឬការយល់ឃើញរបស់អ្នក៖

- ពិការភាពផ្លូវកាយ ឬផ្លូវចិត្ត
- យេនឌ័រ សំដៅលើភេទ និងរួមបញ្ចូលអត្តសញ្ញាណយេនឌ័រ និងការបង្ហាញលក្ខណៈយេនឌ័រ។
- សញ្ជាតិ
- ជាតិសាសន៍ ឬជនជាតិ
- សាសនា
- ទំនោរផ្លូវភេទ ឬ
- ទំនាក់ទំនងជាមួយបុគ្គល ឬក្រុមដែលមានលក្ខណៈ "ពិត" ឬ "យល់ឃើញ" មួយឬច្រើនទាំងនេះ។
- ក្រោមច្បាប់រដ្ឋប្បវេណី មានលក្ខណៈអត្តសញ្ញាណមានការការពារបន្ថែម ដែលមិនត្រូវបានរាប់បញ្ចូលនៅទីនេះ។

ជនរងគ្រោះរួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះតែបុគ្គល ក្រុមគ្រួសារ ក្រុម មជ្ឈមណ្ឌលសហគមន៍ មជ្ឈមណ្ឌលអប់រំ អង្គភាព ការិយាល័យ សាលប្រជុំ កន្លែងទីសក្ការៈ ស្ថាប័នឯកជន ទីភ្នាក់ងារសាធារណៈ បណ្ណាល័យ ឬជនរងគ្រោះផ្សេងទៀត ឬជនរងគ្រោះដែលត្រូវបានប៉ះនៃបទល្មើសនោះឡើយ។

**ករណីស្អប់ខ្ពើម** គឺជាសកម្មភាព ឬអាកប្បកិរិយាដែលត្រូវបានជំរុញដោយការស្អប់ ឬលម្អៀងដោយចេតនាចំពោះក្រុមដែលត្រូវបានការពារដែលមិនឈានដល់កម្រិតនៃឧក្រិដ្ឋកម្ម។ សេរីភាពនៃការបញ្ចេញមតិនៅក្រោមរដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិក និងរដ្ឋ California អនុញ្ញាតឱ្យមានវោហាសាស្ត្រស្អប់ខ្ពើម ដរាបណាវាមិនជ្រៀតជ្រែកជាមួយសិទ្ធិស៊ីវិលរបស់អ្នកដទៃ។ អ្នកគួរតែរាយការណ៍អំពីករណីស្អប់ខ្ពើមទៅកាន់ទីភ្នាក់ងារអនុវត្តច្បាប់ក្នុងតំបន់របស់អ្នក។ ប្រសិនបើករណីស្អប់ខ្ពើមកើនឡើងដល់ការគំរាមកំហែង ឬសកម្មភាពឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិ នោះវាអាចត្រូវបានចាត់ថ្នាក់ថាជាឧក្រិដ្ឋកម្មស្អប់ខ្ពើមបាន។ អ្នកក៏អាចមានសិទ្ធិទទួលបានការសង្គ្រោះផ្នែកស៊ីវិលផងដែរ ប្រសិនបើអ្នកទទួលរងករណីស្អប់ខ្ពើម។

ឧទាហរណ៍នៃករណីស្អប់ខ្ពើមរួមមាន៖

- ការហៅឈ្មោះ ការប្រមាថ ពាក្យបង្កាច់ ការបញ្ចេញមតិបង្ខូចកេរ្តិ៍ឈ្មោះ និងពាក្យអសុរស ដែលត្រូវបានដាក់ជាប់នៅនឹងក្រុមដែលត្រូវបានការពារដែលមិនគំរាមកំហែងអំពើហិង្សា។
- ការតាំងបង្ហាញសម្ភារៈដែលគួរឱ្យស្អប់នៅលើអចលនទ្រព្យ ផ្ទាល់របស់ជនណាម្នាក់ដែលមិនគំរាមកំហែងអំពើហិង្សា។

- ស្លៀកសម្លៀកបំពាក់ដែលមានសារស្អប់ខ្ពើមដែលមិនគំរាមកំហែងអំពើហិង្សា។
- ការចែកចាយសម្ភារដែលមានសារស្អប់ខ្ពើមនៅទីសាធារណៈដែលមិនគំរាមកំហែងអំពើហិង្សា។

## *តើធ្វើដូចម្តេចដើម្បីសម្គាល់ដឹងនូវឧក្រិដ្ឋកម្មស្អប់ខ្ពើម៖*

សញ្ញាដែលបង្ហាញថាឧក្រិដ្ឋកម្មត្រូវបានជំរុញដោយការស្អប់ខ្ពើម ឬការលម្អៀងអាចរួមមាន៖

- ជនល្មើសបានជ្រើសរើសជនរងគ្រោះ ឬអចលនទ្រព្យ ដោយសារតែពួកគេជាកម្មសិទ្ធិរបស់ក្រុមមានការការពារ ឧ. សាសនា ពូជសាសន៍ ឬយេនឌ័រជាក់លាក់ខ្លះ។
- ជនល្មើសបានធ្វើការបញ្ចេញមតិជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ដែលបង្ហាញពីបុរេវិនិច្ឆ័យ ឧ. ពាក្យមួលបង្កាច់ និមិត្តសញ្ញា។
- ឧក្រិដ្ឋកម្មបានកើតឡើងនៅទីតាំងដែលមានសារៈសំខាន់សម្រាប់ក្រុមមានការការពាររបស់ជនរងគ្រោះ ឧ. ផ្ទះជាទីសក្ការៈ មជ្ឈមណ្ឌលសហគមន៍ ក្បួនដង្ហែ ឬការប្រារព្ធខាងវប្បធម៌។
- ឧក្រិដ្ឋកម្មនេះបានកើតឡើងនៅថ្ងៃដែលមានសារៈសំខាន់សម្រាប់ក្រុមមានការពាររបស់ជនរងគ្រោះ ឧ. ថ្ងៃឈប់សម្រាកបុណ្យសាសនា ថ្ងៃឈប់សម្រាកបុណ្យវប្បធម៌ ដូចជាបុណ្យចូលឆ្នាំចិន ឬការប្រារព្ធពិធីអបអរមោទនភាព ឬថ្ងៃគម្រប់ខួប។
- មានសកម្មភាពស្អប់ខ្ពើមដែលត្រូវបានរៀបចំនៅក្នុងតំបន់។

## *ប្រសិនបើអ្នកស្ថិតក្នុងគ្រោះថ្នាក់ សូមហៅទូរសព្ទទៅលេខ 911 ឬទាក់ទងទីភ្នាក់ងារអនុវត្តច្បាប់ក្នុងតំបន់របស់អ្នកភ្លាមៗ។ នៅពេលដែលអ្នកលែងស្ថិតក្នុងគ្រោះថ្នាក់តទៅទៀតហើយ ហើយបានទទួលការយកចិត្តទុកដាក់ខាងវេជ្ជសាស្ត្រដែលត្រូវការណាមួយ ប្រសិនបើអាចធ្វើបាន អ្នកអាច៖*

- រក្សាទុកភស្តុតាងរូបវ័ន្តណាមួយ ឧ. គំនូរនៅតាមទីសាធារណៈ វត្ថុដែលខូចបាក់បែក ឬវត្ថុដែលចោល សរសេរអ្វីគ្រប់យ៉ាងដែលអ្នកចងចាំ ហើយថតរូប។
- យកឲ្យបានឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់ជនរងគ្រោះ និងសាក្សីផ្សេងទៀត និងការពិពណ៌នា និងព័ត៌មានណាមួយក៏ដោយដែលពួកគេអាចនឹងមានអំពីជនល្មើស។

## *ប្រសិនបើអ្នកឃើញដោយផ្ទាល់ភ្នែកនូវឧក្រិដ្ឋកម្មស្អប់ខ្ពើម អ្នកគួរតែរាយការណ៍ពីឧក្រិដ្ឋកម្មនេះទៅទីភ្នាក់ងារអនុវត្តច្បាប់ក្នុងតំបន់របស់អ្នក។*

- ក្រសួងយុត្តិធម៌រដ្ឋ California មានឧបករណ៍ និងធនធានដើម្បីជ្រោមជ្រែង និងជួយអាជ្ញាធរអនុវត្តច្បាប់ក្នុងតំបន់ រដ្ឋ និងសហព័ន្ធក្នុងការស៊ើបអង្កេតឧក្រិដ្ឋកម្មស្អប់ខ្ពើមដែលអាចមាន រួមទាំងការកំណត់អត្តសញ្ញាណ ការចាប់ខ្លួន ការកាត់ទោស និងការផ្តន្ទាទោសឧក្រិដ្ឋជននៃឧក្រិដ្ឋកម្មទាំងនោះ។

## *អ្វីដែលអ្នក និងសហគមន៍របស់អ្នកអាចធ្វើដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើស្អប់ខ្ពើម៖*

- **យល់ពីបញ្ហា។** ភាគីពាក់ព័ន្ធទាំងអស់អាចធ្វើការរួមគ្នាដើម្បីយល់ពីបញ្ហាក្នុងតំបន់ ដើម្បីបង្កើតដំណោះស្រាយ។
- **ហ៊ាននិយាយចេញ និងបង្កើនការយល់ដឹង។** ថ្កោលទោសជាសាធារណៈចំពោះអំពើស្អប់ខ្ពើមនិងការមិនអត់ឱន ហើយសុំឱ្យមន្ត្រីសាធារណៈធ្វើដូចគ្នា ។
- **ជំរុញភាពជាដៃគូផ្នែកអនុវត្តច្បាប់-សហគមន៍។** ភាពជាដៃគូផ្នែកអនុវត្តច្បាប់-សហគមន៍រឹងមាំអាចមានប្រសិទ្ធភាពខ្ពស់ក្នុងការទប់ស្កាត់ និងឆ្លើយតបយ៉ាងត្រឹមត្រូវចំពោះឧក្រិដ្ឋកម្មស្អប់ខ្ពើម។

- **គណៈកម្មការទំនាក់ទំនងមនុស្ស** អាចលើកកម្ពស់ការយល់ដឹងរបស់សហគមន៍ ផ្តល់ការគាំទ្រដល់ជនរងគ្រោះ និងធ្វើការដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មស្អប់ខ្ពើម និងករណីស្អប់ខ្ពើម នាពេលអនាគត។ ពួកគេក៏អាចអប់រំអ្នកអនុវត្តច្បាប់ និងសាធារណជនអំពីឧក្រិដ្ឋកម្មស្អប់ខ្ពើម និងករណីស្អប់ខ្ពើម តាមដាននិន្នាការ និងតស៊ូមតិដើម្បីធ្វើការផ្លាស់ប្តូរគោលនយោបាយផងដែរ។

## *ព័ត៌មានសម្រាប់ជនរងគ្រោះ៖*

សេចក្តីប្រកាសពីសិទ្ធិឯកជនរបស់ជនរងគ្រោះនៃរដ្ឋ California (Cal. Const., art I, § 28) ដែលគេស្គាល់ថាជាច្បាប់ Marsy និងក្រមព្រហ្មទណ្ឌផ្តល់ឱ្យអ្នកនូវសិទ្ធិផ្លូវច្បាប់សំខាន់ៗនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ នៅពេលដែលអ្នកជាជនរងគ្រោះនៃឧក្រិដ្ឋកម្មស្អប់ខ្ពើម ។ ជនរងគ្រោះនៃឧក្រិដ្ឋកម្មស្អប់ខ្ពើម និងករណីស្អប់ខ្ពើមក៏អាចមានសិទ្ធិទទួលបានសំណងរដ្ឋប្បវេណីតាមរយៈតុលាការស៊ីវិល[i] ក្រោមច្បាប់ស្តីពីសិទ្ធិស៊ីវិល Ralph (ក្រមរដ្ឋប្បវេណីត្រង់មាត្រាទី § 51.7) និងច្បាប់ស្តីពីសិទ្ធិស៊ីវិល Tom Bane (ក្រមរដ្ឋប្បវេណីត្រង់មាត្រាទី § 52.1)។

- **សិទ្ធិទទួលបានការទូទាត់សម្រាប់ការខាតបង់របស់អ្នក។** នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ អ្នកអាចស្វះស្វែងរក និងយកឲ្យបាននូវសំណងដើម្បីទូទាត់ការខាតបង់ទ្រព្យសម្បត្តិ ការចំណាយវេជ្ជសាស្ត្ររបស់អ្នក រួមទាំងសំណងសម្រាប់ការចំណាយសមរម្យនៃការផ្តល់ប្រឹក្សា ប្រាក់ឈ្នួលដែលបាត់បង់ និងការខាតបង់ផ្សេងៗទៀត។ នៅក្នុងសំណុំរឿងរដ្ឋប្បវេណី តុលាការក៏អាចនឹងផ្តល់ឲ្យនូវដីកាឱ្យសងអ្នកវិញសម្រាប់ការខាតបង់ជាក់ស្តែង បន្ថែមពីលើការខាតបង់ដែលមិនមែនសេដ្ឋកិច្ច ដូចជាការរងទុក្ខលំបាកខាងផ្លូវចិត្តជាដើម។ តុលាការរដ្ឋប្បវេណីអាចនឹងបញ្ជាឲ្យអ្នកដែលបានធ្វើបាបអ្នក ជាភាគីចុងចោទ បង់ជូនអ្នកនូវថ្លៃជំងឺចិត្តសម្រាប់ប្រដៅ ឬសម្រាប់ដាក់ទណ្ឌកម្ម បង់ថ្លៃសេវាមេធាវីរបស់អ្នកប្រសិនបើអ្នកបានជួលមេធាវីឱ្យជួយដោះស្រាយសំណុំរឿងរដ្ឋប្បវេណីរបស់អ្នក និង/ឬបង់ប្រាក់ឱ្យអ្នកចំនួន $25,000 សម្រាប់ការរំលោភសិទ្ធិស៊ីវិលរបស់អ្នក។
- **សិទ្ធិក្នុងការចែករំលែករឿងរ៉ាវរបស់អ្នក។** នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ អ្នកអាចប្រាប់តុលាការថាតើឧក្រិដ្ឋកម្មនេះប៉ះពាល់ដល់ជីវិតរបស់អ្នកយ៉ាងដូចម្តេចបានមុនពេលចុងចោទត្រូវបានកាត់ទោស។
- **សិទ្ធិទទួលបានព័ត៌មានអំពីសំណុំរឿងព្រហ្មទណ្ឌ។** អ្នកមានសិទ្ធិទទួលបានព័ត៌មានជាក់លាក់អំពីសំណុំរឿងព្រហ្មទណ្ឌពីរដ្ឋអាជ្ញា រួមមានប៉ុន្តែមិនកំណត់ត្រឹមចំពោះតែព័ត៌មានខាងក្រោមនេះទេ៖ (1) ការចាប់ខ្លួនជនជាប់ចោទ (2) ការចោទប្រកាន់ត្រូវបានដាក់ (3) ការផ្តន្ទាទោស ការកាត់ទោស និង/ឬ ការដាក់ពន្ធនាគារនៃចុងចោទ ហើយប្រសិនបើអាចអនុវត្តបាន (4) កាលបរិច្ឆេទដោះលែងចុងចោទដែលបានកំណត់ពេល។ អ្នកក៏អាចនឹងស្នើសុំឱ្យទទួលបានការជូនដំណឹងសមហេតុផលអំពីដំណើរការជម្រះក្តីសាធារណៈ និងការដោះលែងដោយមានលក្ខខណ្ឌ ឬដំណើរការជម្រះក្តីដោះលែងក្រោយការកាត់ទោសផ្សេងទៀតផងដែរ។
- **សិទ្ធិទទួលបានជំនួយពីតុលាការដើម្បីសុវត្ថិភាព។** តុលាការអាចចេញដីកាដែលអាចជួយអ្នក ដូចជាដីការក្សាការពារ ឬបញ្ជាឲ្យឈប់បទឧក្រិដ្ឋ ឬបទរដ្ឋប្បវេណីដើម្បីការពារអ្នក ក្រុមគ្រួសារផ្ទាល់របស់អ្នក ឬដៃគូក្នុងគ្រួសាររបស់អ្នកពីអំពើហិង្សា ការគំរាមកំហែង ការតាមប្រមាញ់ ឬការបៀតបៀនតទៅទៀតដោយចុងចោទ រួមទាំងដីការក្សាឱ្យជនជាប់ចោទនៅឆ្ងាយពីអ្នក។
- **សិទ្ធិឯកជនភាពទាក់ទងនឹងឋានៈអន្តោប្រវេសន៍របស់អ្នក។** ប្រសិនបើអ្នកជាជនរងគ្រោះ ឬសាក្សីចំពោះឧក្រិដ្ឋកម្មស្អប់ខ្ពើម ផ្នែកអនុវត្តច្បាប់អាចនឹងមិនឃុំខ្លួនអ្នកដោយសាររំលោភលើច្បាប់អន្តោប្រវេសន៍ជាក់ស្តែង ឬសង្ស័យ ឬរាយការណ៍អ្នកទៅអាជ្ញាធរអន្តោប្រវេសន៍សហព័ន្ធទេ លុះត្រាតែអ្នកត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសពីបទប្រព្រឹត្តឧក្រិដ្ឋកម្មមួយចំនួននៅក្រោមច្បាប់រដ្ឋ។ ច្បាប់រដ្ឋ California ហាមប្រាមអាជ្ញាធរអនុវត្តច្បាប់មិនឲ្យសាកសួរបុគ្គល រួមទាំងអ្នកដែលកំពុងរាយការណ៍ ឬជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលអាចកើតមានអំពីឋានៈអន្តោប្រវេសន៍របស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលដែលស្វែងរកការទទួលបានទិដ្ឋាការប្រភេទ U (ទិដ្ឋាការសម្រាប់ជនរងគ្រោះឧក្រិដ្ឋកម្ម) ឬទិដ្ឋាការប្រភេទ T (ទិដ្ឋាការសម្រាប់ជនរងគ្រោះពីការជួញដូរមនុស្ស) អាចមានបំណងចង់ផ្តល់ព័ត៌មានអំពីឋានៈអន្តោប្រវេសន៍របស់ពួកគេដល់អាជ្ញាធរអនុវត្តច្បាប់ ដើម្បីទទួលការបញ្ជាក់ទទួលស្គាល់សម្រាប់ទិដ្ឋាការប្រភេទ U ឬទិដ្ឋាការប្រភេទ T។

---

i មានតែរដ្ឋាភិបាលទេដែលអាចកាត់ទោសសំណុំរឿងព្រហ្មទណ្ឌបាន។ ការទោសក្នុងសំណុំរឿងព្រហ្មទណ្ឌអាចនឹងរួមមាន ប៉ុន្តែមិនកំណត់ត្រឹមចំពោះតែរយៈពេលជាប់ពន្ធនាគារ ការផាកពិន័យ ឬការដាក់ពិន័យ ឬលក្ខខណ្ឌផ្សេងទៀត ជំនួសឱ្យរយៈពេលជាប់ពន្ធនាគារនោះឡើយ។ ផ្ទុយទៅវិញ សំណុំរឿងរដ្ឋប្បវេណីអាចត្រូវបានដាក់ដោយបុគ្គល អង្គភាព ឬរដ្ឋាភិបាល។ សំណុំរឿងរដ្ឋប្បវេណីដោះស្រាយវិវាទទាក់ទងនឹងច្បាប់រដ្ឋប្បវេណី ហើយបន្ទុកភស្តុតាងដាក់អនុវត្តតិចជាងករណីព្រហ្មទណ្ឌ។ ការចូលពន្ធនាគារមិនមែនជាផលវិបាកក្នុងសំណុំរឿងរដ្ឋប្បវេណីទេ។

## *កន្លែងដែលត្រូវស្វែងរកជំនួយ៖*

- **សូមទាក់ទង 911 ឬទៅមន្ទីរពេទ្យក្នុងតំបន់ប្រសិនបើអ្នកត្រូវការការយកចិត្តទុកដាក់ខាងវេជ្ជសាស្ត្រភ្លាម។ ដើម្បីដាក់របាយការណ៍ សូមទាក់ទងទីភ្នាក់ងារអនុវត្តច្បាប់ក្នុងតំបន់របស់អ្នក។**

- ***ខ្សែទូរសព្ទ និងបណ្ដាញធនធាន* CA vs. Hate**
  *CA vs. Hate* មិនមែនជាខ្សែទូរសព្ទរាយការណ៍អំពីការអនុវត្តច្បាប់ទេ ប៉ុន្តែអ្នកអាចរាយការណ៍អំពីឧក្រិដ្ឋកម្មស្អប់ខ្ពើម និងករណីស្អប់ខ្ពើមបានតាមរយៈលេខ (833) 866-4283 ឬរាយការណ៍តាមអ៊ីនធឺណិតនៅលើគេហទំព័រ https://stophate.calcivilrights.ca.gov/s/ ។ ការរាយការណ៍នេះនឹងបញ្ឈប់ការធ្វើប្រក្រតីភាវូបនីកម្មនៃអំពើស្អប់ខ្ពើមនៅក្នុងសហគមន៍របស់យើង និងធានាថាបុគ្គលដែលរងផលប៉ះពាល់ទទួលបានជំនួយ។ *CA v. Hate* ក៏ផ្ដល់នូវសិទ្ធិចូលប្រើប្រាស់ធនធាន និងការគាំទ្រដែលមានសមត្ថកិច្ចខាងវប្បធម៌សម្រាប់សហគមន៍ និងជនរងគ្រោះផងដែរ។

- **អង្គភាពសេវាកម្មជនរងគ្រោះនៃការិយាល័យអគ្គរដ្ឋអាជ្ញារដ្ឋ California**
  អង្គភាពសេវាជនរងគ្រោះផ្ដល់ជូនជនរងគ្រោះពីឧក្រិដ្ឋកម្ម និងក្រុមគ្រួសាររបស់ពួកគេនូវជំនួយគាំទ្រនៅគ្រប់ដំណាក់កាលនៃដំណើរការកាត់ទោសព្រហ្មទណ្ឌ។ ចំពោះព័ត៌មានបន្ថែម សូមហៅទូរសព្ទទៅលេខ៖ (877) 433-9069 ឬចូលទៅកាន់គេហទំព័រ៖ oag.ca.gov/hatecrimes។

- **ក្រសួងសិទ្ធិស៊ីវិល(CRD) រដ្ឋ California**
  CRD គឺជាទីភ្នាក់ងាររដ្ឋដែលទទួលបន្ទុកអនុវត្តច្បាប់សិទ្ធិស៊ីវិល Ralph។ ប្រសិនបើអ្នកធ្លាប់ជាជនរងគ្រោះនៃឧក្រិដ្ឋកម្មស្អប់ខ្ពើម ឬករណីស្អប់ខ្ពើម អ្នកអាចដាក់ពាក្យបណ្ដឹងជាមួយ CRD ប្រឆាំងនឹងអ្នកដែលបានធ្វើបាបអ្នក។ ចំពោះព័ត៌មានបន្ថែមអំពីរបៀបដាក់ពាក្យបណ្ដឹង សូមចូលទៅកាន់គេហទំព័រ៖ Calcivilrights.ca.gov/complaintprocess ឬហៅទូរសព្ទទៅលេខ៖ (800) 884-1684 (ឥតគិតថ្លៃ) ឬ (800) 700-2320 (TTY)។

- **មជ្ឈមណ្ឌលជំនួយសាក្សីជនរងគ្រោះនៃការិយាល័យមេធាវីមណ្ឌលក្នុងមូលដ្ឋាន**
  ខោនធីនីមួយៗ និងទីក្រុង Los Angeles មានមជ្ឈមណ្ឌលជំនួយសាក្សីជនរងគ្រោះ ដែលធ្វើការដោយផ្ទាល់ជាមួយគណៈកម្មការសំណងជនរងគ្រោះនៃរដ្ឋ California ដើម្បីជួយជនរងគ្រោះ។ ចំពោះព័ត៌មានអំពីការិយាល័យ និងធនធានក្នុងមូលដ្ឋាន សូមចូលទៅកាន់គេហទំព័រ៖ victims.ca.gov/victims/localhelp.aspx។